# ការយកសំណាកគ្រាប់ស្រូវ-អង្ករ

Grain Sampling

**តើអ្វីទៅជាការយកសំណាក?** What is grain sampling?

ការយកសំណាក គឺជាដំណើរការជ្រើសរើសគ្រាប់ធញ្ញជាតិមួយចំណែកតូចពីបរិមាណដ៏ច្រើន ពីវាលស្រែ ពីគំនរឬពីក្នុងបាវ ។ គោលបំណងនៃ ការយកសំណាកត្រឹមត្រូវ គឺជាការប្រមូលនូវ " **សំណាកតំណាង**" មានន័យថា ភាគរយនៃគ្រាប់ធញ្ញជាតិដែលមានលក្ខណៈខុសគ្នា( ឧ.សំណើមគ្រាប់) នៅក្នុងសំណាក ដូចគ្នាទៅនឹងឡូត៍ឬគំនរដែលសំណាកត្រូវបានយកចេញ ។

**ហេតុអ្វីបានជាការយកសំណាកត្រឹមត្រូវ មានសារៈសំខាន់?** Why is proper grain sampling important?

ស្រូវ គឺជាសារធាតុវិសភាគ និងដោយសារតែទំហំវាលស្រែតូច និងការប្រើប្រាស់ប្រភេទខុសៗគ្នាជាច្រើនក្នុងប្រទេសជាច្រើននៅអាស៊ី ទើបធ្វើអោយស្រូវឬអង្ករដែលរក្សានៅក្នុងឡូត៍ គំនរ ឬឃ្លាំងអាចលាយឡំគ្នាយ៉ាងច្រើន ។ សូម្បីតែក្នុងវាលស្រែតែមួយអត្រាសំណើមក៏អាចខុសគ្នាដែរនៅក្នុងកន្លែងតែមួយ ។ ដូច្នេះវិធីសាស្ត្រយកសំណាកអោយបានត្រឹមត្រូវ គឺជាការសំខាន់ណាស់ដើម្បីទទួលបានសំណាកតំណាងទាំងមូល ។

**របៀបយកសំណាកអោយបានត្រឹមត្រូវ?** How to sample properly?

**សំណាកនៅវាលស្រែ** Field sample

ដើម្បីទទួលបានសំណាកតំណាងនៅវាលស្រែមុនពេលច្រូតកាត់ជាការលំបាក :

- ពេលដែលជួរខាងក្រៅខុសពីធម្មតា ចូរដើរកាត់វាលស្រែតាមធម្មតា
- ដៃបេះ និងប្រឡេះគ្រាប់ស្រូវចេញ ពី ៤-៥ គុម្ព ហើយច្របល់សំណាកចូលគ្នា
- មើលយ៉ាងតិចណាស់ ៣ដង ដើម្បីរកតំលៃមធ្យម ។

**សំណាកគ្រាប់ផ្ទុកក្នុងឃ្លាំង** Grain load sample

ពេលដែលយកសំណាកគ្រាប់ស្រូវផ្ទុកក្នុងឃ្លាំងច្រើនកន្លែង (ជៀសវាងយកកណ្តាល និងកាច់ជ្រុង) ឬ យកសំណាកគ្រាប់ដែលហូរចុះមកពីគំនរ អំឡុងពេលផ្ទុក ឬផ្ទេរ :

- ដាក់កំប៉ុងឆ្លងកាត់លំហូរគ្រាប់ស្រូវក្នុងចន្លោះមួយជាក់លាក់ និងប្រមូលគ្រាប់ចូលក្នុងធុង
- បន្ទាប់ពីការផ្ទុកនិងការផ្ទេរបានបញ្ចប់ ត្រូវច្របល់គ្រាប់ក្នុងធុង ក្រោយមកចាក់សំណាកចេញ ។

**សំណាកស្រូវក្នុងធុង** Bin sample

ប្រដាប់ចាក់ប្រមូលសំណាកពីជំរៅផ្សេងៗគ្នានឹងផ្តល់អោយនូវសំណាកតំណាងមួយជាក់លាក់ពេលយកសំណាកក្នុងធុង :

- សំណាកពីក្នុងធុងផ្តល់ទៅជាផ្នែកមួយតំណាងអោយទំហំស្រូវទាំងមូល
- ចូរកុំច្របល់សំណាកចូលគ្នា និងធ្វើតេស្តដាច់ដោយឡែកពីគ្នា ។ ចូរគិតថាលក្ខណៈសំណាកនៅទីតាំងខុសៗគ្នានឹងជួយក្នុងការធ្វើការសំរេចចិត្តបានល្អប្រសើរ ។

**សំណាកនៅក្នុងបាវ** Sack Sample



ប្រសិនបើគ្រាប់ពូជត្រូវបានគេធ្វើតេស្តពីឡូត៍ដែលមានច្រើនបាវ សំណាកគួរតែត្រូវបានយកចេញពីបាវមួយចំនួន ។ តាមការពិសោធន៍ដ៏ត្រឹមត្រូវក្នុងការកំណត់ចំនួនបាវដើម្បីយកសំណាកគឺត្រូវតែយកសំណាកពីចំនួនបាវដែលតំណាងឬសការេនៃទំហំឡូត៍ទាំងមូល ។ ឧទាហរណ៍ : ប្រសិនបើ ឡូត៍មាន ៩បាវ ពេលនោះសំណាកត្រូវយកយ៉ាងហោចណាស់ ៣បាវ បើឡូត៍មាន ១០០បាវ ពេលនោះ សំណាកត្រូវយកយ៉ាងហោចណាស់ ១០បាវ ។

**ការធ្វើតេស្តសំណាក** Treatment of samples

ត្រូវធ្វើតេស្តសំណាកដែលយកមកអោយបានឆាប់រហ័សព្រោះការផ្លាស់ប្តូរសំណើម និងគុណភាពកើតឡើងរាល់ពេល :

-ត្រូវបិទគំរបកំប៉ុងដាក់សំណាកឬបិទមាត់ថង់ប្លាស្ទិចភ្លាមបន្ទាប់ពីយកសំណាករួចដើម្បីរក្សាអត្រាសំណើមពេលយក។

-ប្រសិនបើស្តុកទុកបណ្តុះអាសន្នត្រូវទុកវានៅក្នុងទូទឹកកក ឬបន្ទប់ត្រជាក់ ។

-ត្រូវដាក់ផ្លាកសញ្ញាសមរម្យដែលប្រើប៊ិចមិនរលុប សសេរ ឬបិទ នៅលើកំប៉ុងដាក់សំណាក

នៅពេលនាំសំណាកពូជស្រូវទៅក្រៅប្រទេសត្រូវពិនិត្យបទដ្ឋានពូជស្រូវក្នុងស្រុកដោយឡែកមួយផ្សេងទៀត ។